# ការបញ្ចុះបញ្ចូល

## ក) សេចក្តីផ្តើម:

សកម្មភាពសំខាន់បំផុតនៃការចូលរួមផ្នែកនយោបាយតាមបែបប្រជាធិបតេយ្យ កើតមានឡើងនៅពេលដែលប្រជាពលរដ្ឋជ្រើសរើសតំណាងរបស់ខ្លួន (តំណាងរាស្ត្រ អ្នកធ្វើច្បាប់) ។ ប៉ុន្តែ **ការចូលរួមផ្នែកនយោបាយ** របស់ប្រជាពលរដ្ឋនៅក្នុងប្រទេសប្រជាធិបតេយ្យមួយ **មិនមែនបញ្ចប់ជាមួយនឹងការបោះឆ្នោតនោះទេ** ដោយហេតុថា ការចូលរួមជាបន្ត គឺមានការចាំបាច់ក្នុងគ្រប់រយៈពេលទាំងអស់រហូតដល់មានការបោះឆ្នោតបន្ទាប់មកទៀត ។

មានហេតុផលជាច្រើន ចំពោះ**តំរូវការឱ្យមានការចូលរួមផ្នែកនយោបាយជាប្រចាំ**ដោយសារៈ

- ឆន្ទៈនយោបាយរបស់អ្នកបោះឆ្នោតអាចប្រែប្រួល ។
- ស្ថានភាពអាចប្រែប្រួលៈ បញ្ហាថ្មីៗអាចកើតឡើង ។
- ច្បាប់ចាស់អាចប្រើការលែងកើត ច្បាប់ថ្មីក្លាយជាច្បាប់ដែលគេត្រូវការជាចាំបាច់ ។
- កម្មវិធី និងសកម្មភាពនយោបាយ របស់គណបក្សនយោបាយ ប្រហែលជាមិនត្រូវបានបកស្រាយទៅជាសកម្មភាពរបស់រដ្ឋាភិបាល

ហេតុដូច្នេះ លទ្ធិប្រជាធិបតេយ្យដែលមានប្រសិទ្ធិភាព តំរូវឱ្យស្ថាប័ននយោបាយនានា (តំណាងរាស្ត្រ រដ្ឋាភិបាល) **ធ្វើការប្រាស្រ័យទាក់ទងជាមួយប្រជាជន**ក្នុងចន្លោះពេលបោះឆ្នោត និងឆ្លើយតបទៅនឹងទស្សនៈយល់ឃើញរបស់ពួកគេ ។ បើមិនដូច្នោះទេ ស្ថាប័នទាំងនេះនិងបាត់បង់ការប្រាស្រ័យទាក់ទងជាមួយនឹងការពិតជាក់ស្តែង ។ ពួកគេនឹងមិនទទួលបានប្រតិកម្ម ឬធនធានបញ្ចូលណាមួយពីសង្គម ប្រសិនបើស្ថាបន័នយោបាយទាំងនេះមិនសាកសួរប្រជាជន អំពីការយល់ឃើញរបស់ពួកគេ និងមិនស្តាប់យោបល់របស់ប្រជាជន ។

នេះជាហេតុផលដែល**ការសន្ទនាជាប្រចាំមួយរវាងសង្គម** (អ្នកបោះឆ្នោត ក្រុមដែលពាក់ព័ន្ធ សមាគមពលរដ្ឋម្នាក់ៗ អង្គការក្រៅរដ្ឋាភិបាល សង្គមស៊ីវិល) និងស្ថាប័នលទ្ធិប្រជាធិបតេយ្យនានា ត្រូវមានជាចាំបាច់ ។ ជាបឋម ត្រូវមានការសន្ទនាជាមួយ**រដ្ឋសភា**ដែលជាស្ថាប័នមួយដែលមានអំណាចបង្កើតច្បាប់ ប៉ុន្តែជាការពិតណាស់ ក៏ត្រូវមានការសន្ទនាផងដែរជាមួយស្ថាប័នទាំងនោះ ដែលយ៉ាងហោចណាស់ មានសិទ្ធិផ្តួចផ្តើមបង្កើតច្បាប់ឡើង (រដ្ឋាភិបាល ព្រឹទ្ធសភា) ។



## ២) មូលដ្ឋានរដ្ឋធម្មនុញ្ញសំរាប់ការចូលរួមផ្នែកនយោបាយៈ

រដ្ឋធម្មនុញ្ញកម្ពុជាបានចែងយ៉ាងច្បាស់ថា ការចូលរួមរបស់ប្រជាជនក្នុងជីវិតនយោបាយ គឺមិនមែនត្រឹមតែជាសិទ្ធិរបស់ពួកគេប៉ុណ្ណោះទេ វាថែមទាំងជា គោលការណ៍មួយក្នុងចំណោមគោលការណ៍ជាមូលដ្ឋានរបស់លទ្ធិ-ប្រជាធិបតេយ្យនៅកម្ពុជា ហើយការចូលរួមនេះ ត្រូវបានគេស្វាគមន៍យ៉ាងខ្លាំងក្លា ។

ដូច្នេះ រដ្ឋធម្មនុញ្ញ មិនត្រឹមតែបានផ្តល់នូវសិទ្ធិចូលរួមយ៉ាងសកម្មក្នុងនាមជាបេក្ខជនឈរឈ្មោះ ឬ **អ្នកបោះឆ្នោត** ក្នុងកំឡុងពេលបោះឆ្នោតប៉ុណ្ណោះទេៈ

> មាត្រា ៣៤ I CC:
>
> ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិបោះឆ្នោត និងអាចឈរឈ្មោះឱ្យគេបោះឆ្នោត ។

ប៉ុន្តែ មាត្រាជាច្រើននៃរដ្ឋធម្មនុញ្ញក៏បានចែងផងដែរថា ប្រទេសកម្ពុជាបានប្តេជ្ញាចិត្តឱ្យមាន **គណបក្សចំរុះ ប្រជាធិបតេយ្យសេរី និងពហុបក្ស** ។ នេះមានន័យថា គេត្រូវស្តាប់ និងគិតពិចារណាគ្រប់ការបញ្ចេញយោបល់ផ្សេងៗគ្នាទាំងអស់ៈ

> បុព្វកថានៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាៈ
>
> ....ស្តាប្រទេសកម្ពុជាឱ្យទៅជា "កោះសន្តិភាព" ដោយអាស្រ័យទៅលើរបបប្រជាធិបតេយ្យពហុបក្ស ដែលធានាដល់សិទ្ធិមនុស្ស និងការគោរពច្បាប់ ។
>
> មាត្រា១ CC:
>
> ប្រទេសកម្ពុជា ជាព្រះរាជាណាចក្រដែលព្រះមហាក្សត្រ ទ្រង់ប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ និងតាមលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ។
>
> មាត្រា៥០ CC:
>
> ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ត្រូវគោរពគោលការណ៍អធិបតេយ្យជាតិ និងលទ្ធិប្រជាធិប-តេយ្យសេរីពហុបក្ស។
>
> មាត្រា ៥១ CC:
>
> ព្រះរាជាណាចក្រកម្ពុជា អនុវត្តរបបនយោបាយប្រជាធិបតេយ្យសេរីពហុបក្ស ។
> ប្រជាពលរដ្ឋខ្មែរ ជាម្ចាស់វាសនានៃប្រទេសជាតិខ្លួន ។
> អំណាចទាំងអស់ ជារបស់ប្រជាពលរដ្ឋ ។

សេរីពហុបក្សនេះ មានន័យថា ស្ថាប័នទាំងឡាយរបស់រដ្ឋក៏ត្រូវស្តាប់**ការបញ្ចេញយោបល់ផ្ទុយគ្នា ប្តឹងតវ៉ា** និង **ការរិះគន់**ផងដែរ ។

> មាត្រា៣៩ CC:
>
> ប្រជាពលរដ្ឋខ្មែរ មានសិទ្ធិប្តឹងបរិហារ ប្តឹងតវ៉ា ឬប្តឹងទារសំណងជួសជុលការខូចខាត ដែលបណ្តាលមកពីអំពើខុសច្បាប់របស់អង្គការរដ្ឋ របស់អង្គការសង្គម និងរបស់បុគ្គលិកនៃអង្គការទាំងនោះ ។ ការដោះស្រាយបណ្តឹងតវ៉ា និងសំណងជួសជុលការខូចខាត ជាសមត្ថកិច្ចរបស់តុលាការ ។

ជាចុងក្រោយ រដ្ឋធម្មនុញ្ញបានផ្តល់យ៉ាងជាក់លាក់នូវ**សិទ្ធិសំរាប់ពលរដ្ឋគ្រប់រូប ក្នុងការចូលរួមក្នុងជីវិភាពនយោបាយ**នៃជាតិកម្ពុជា ។

> មាត្រា ៣៥ CC:
>
> ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ប្រទេសជាតិ ។ សេចក្តីស្នើទាំងឡាយរបស់ប្រជាពលរដ្ឋ ត្រូវបានទទួលការពិនិត្យ និងដោះស្រាយយ៉ាងហ្មត់ចត់ពីអង្គការរដ្ឋ ។

ដូច្នេះ រដ្ឋធម្មនុញ្ញបានគាំទ្រយ៉ាងជាក់ច្បាស់ចំពោះសកម្មភាពបញ្ចុះបញ្ចូលទាំងឡាយ ។ លើសពីនេះទៅទៀត សិទ្ធិមួយចំនួនក្នុងចំណោមសិទ្ធិចូលរួមផ្នែកនយោបាយ ផ្តល់ឱ្យមាននូវមូលដ្ឋានគ្រឹះផ្នែកច្បាប់សំរាប់សកម្មភាពបញ្ចុះបញ្ចូលៈ

- សិទ្ធិ**ក្នុងការបញ្ចេញមតិ** (មាត្រា៤១ I CC មាត្រា១៩ ICCPR)
- សិទ្ធិ**ជួបជុំ** និង**ធ្វើបាតុកម្ម** (មាត្រា៤១ I និង មាត្រា៣៧ CC; មាត្រា២១ ICCPR)
- និង សិទ្ធិសំខាន់បំផុតស្តីពី**ការបង្កើតសមាគម** (មាត្រា ៤២ I, II CC មាត្រា ២២ ICCPR) ។

## គ) និយមន័យនៃការបញ្ចុះបញ្ចូល

តើអ្វីជាកាបញ្ចុះបញ្ចូល? ការបញ្ចុះបញ្ចូលគឺជា **ទំរង់ជាក់លាក់មួយនៃការចូលរួម**ក្នុងជីវិតនយោបាយ ។ ក្នុងខណៈដែល "ការតស៊ូមតិ" ជាពាក្យមួយដែលមានលក្ខណៈទូទៅជាង ដែលសំដៅចំពោះវិធានការណាមួយដើម្បីឱ្យមានការផ្លាស់ប្តូរ ឥរិយាបថ អាកប្បកិរិយា និងគំនិតយល់ឃើញផ្នែកនយោបាយ ។ "ការបញ្ចុះបញ្ចូល" មាន**ទិសដៅជាក់លាក់សំដៅជះឥទ្ធិពលលើដំណើរការបង្កើតច្បាប់** ។ នេះមានន័យថា ផ្តួចផ្តើមឱ្យមានផ្លាស់ប្តូរ ឬធ្វើវិសោធនកម្មច្បាប់ ។

ពាក្យ "បញ្ចុះបញ្ចូល (Lobbying)" មានប្រភពមកពីពាក្យ "Lobby" ដែលមានន័យថា ច្រកធំសំរាប់ចូលទៅក្នុងសាល ។ ពាក្យ "បញ្ចុះបញ្ចូល" មានសារតាជាប្រវត្តិសាស្ត្រមួយៈ ពាក្យនេះសំដៅទៅរកសកម្មភាពទាំងឡាយរបស់អ្នកដែលពាក់ព័ន្ធ ប្រជាពលរដ្ឋ និងតំណាងរបស់ក្រុមដែលមានផលប្រយោជន៏ ដែលមានឥទ្ធិពល ដែលនៅក្នុងសម័យដើម នៃសភាអង់គ្លេសបានព្យាយាម ជួបជាមួយអ្នកតំណាងទាំងឡាយនៅតាមច្រកចូលសាល (របៀង) របស់សភា ដើម្បី**អូសទាញ**ពួកគេឱ្យ**ធ្វើវិសោធនកម្មច្បាប់ ឬបង្កើតច្បាប់ថ្មី** ។ ជាការពិតណាស់ នាពេលបច្ចុប្បន្ននេះ សកម្មភាពបញ្ចុះបញ្ចូលទាំងឡាយមិនមានកើតមាននៅតាមច្រក ចូលសាលសភាទៀតទេ ប៉ុន្តែកើតមាននៅតាមករិត និងទីកន្លែងផ្សេងៗគ្នាជាច្រើន ។

**និយមន័យ:**

ការបញ្ចុះបញ្ចូល គឺជាសកម្មភាពមួយដែលមានទិសដៅ របស់បុគ្គលម្នាក់ របស់អង្គការមួយ ឬរបស់បុគ្គល/អង្គការមួយក្រុម ដែលធ្វើឡើងដើម្បីជះឥទ្ធិពលទៅលើបុគ្គលទាំងអស់ ដែលពាក់ពន្ធ័ក្នុងការរៀបចំច្បាប់ និងអនុមត័ច្បាប់ ។

ការបញ្ចុះបញ្ចូលមានន័យថា:

- លើកបញ្ហាទៅក្នុងរបៀបវារៈរបស់សាធារណជន និងរបស់តំណាងរាស្ត្រ
- ផ្តល់ដំណោះស្រាយសំរាប់បញ្ហានោះ
- សាងការគាំទ្រសំរាប់ដំណោះស្រាយនោះ

## ឃ) ដំណើរការបង្កើតច្បាប់ គឺជាទិសដៅនៃការបញ្ចុះបញ្ចូល:

គេអាចទុកដំណើរការបង្កើតច្បាប់ ថាជាដំណើរការផលិតកម្ម ។ ដំណើរការផលិតកម្មនេះមានបីកំរិត:

- **អ្នកផលិត:** តំណាងរាស្ត្រ
- **ដំណើរការផលិតកម្ម:** ដំណាក់កាលផ្សេងៗគ្នានៃនីតិវិធីបង្កើតច្បាប់
- **ផលិតផលសំរេច:** ច្បាប់

កំរិតនិមួយៗក្នុងចំណោមកំរិតទាំងនេះ អាចជាទិសដៅរបស់សកម្មភាពបញ្ចុះបញ្ចូល:

**តំណាងរាស្ត្រ** អាចត្រូវបានគេជ្រើសរើស ឬជ្រើសរើសសាជាថ្មី ។ អ្នកធ្វើការបញ្ចុះបញ្ចូលអាចអញ្ជើញសាកសួរ ព្យាយាមអូសទាញដោយផ្ទាល់ខ្លួន ធ្វើបទសម្ភាសន៍ពួកគេ និងផ្តល់ពត៌មានសំរាប់ពួកគេ ។

**ដំណើរការបង្កើតច្បាប់** អាចទទួលរងឥទ្ធិពលពីការបើកសវនាការជាសាធារណៈ សំពាធពីសាធារណជន (ប្រពន្ធ័ផ្សព្វផ្សាយពត៌មាន) បាតុកម្ម ការស្ទាបស្ទង់មតិ ហេតុការណ៍ពិត និងពត៌មាន ដែលផ្តល់ជូនស្ថាបន័ស្តីទី (ក្រសួង , គណៈកម្មាការសភា) និងកិច្ចពិភាក្សាជាមួយសមាជិកសភានានា និងគណបក្សនយោបាយទាំងឡាយ ។

**ច្បាប់ដែលជាផលិតផលចុងក្រោយ** អាចទទួលរងការរិះគន់ជាសាធារណៈ ការធ្វើវិសោធនកម្ម អាចត្រូវបានគេស្នើឡើង ។ ការសិក្សារបស់អ្នកជំនាញ អាចបង្ហាញអំពីចំនុចខ្វះខាតនានានៅក្នុងច្បាប់នោះ ។ ការស្ទាប-ស្ទង់មតិ អាចបង្ហាញឱ្យឃើញថា ច្បាប់មួយមិនស្របនឹងការអនុវត្តន៍នៅក្នុងសង្គមជាក់ស្តែង ហើយចុងបញ្ចប់ក្រុមប្រឹក្សារដ្ឋធម្មនុញ្ញ អាចនឹងចូលរួមក្នុងការពិនិត្យច្បាប់ និងប្រកាសច្បាប់នោះថាជាមោឃៈ ប្រសិនបើច្បាប់នោះ មិនស្របនឹងរដ្ឋធម្មនុញ្ញ និងសិទ្ធិមនុស្សនោះទេ ។


សង្គមកម្ពុជា
- ជ្រើសរើស ជ្រើសរើសសាជាថ្មី
- ធ្វើបទសម្ភាសន៍
- ផ្តល់ពតិមាន
- បើកកិច្ចប្រជុំ
តំណាងរាស្ត្រ
- មតិយល់ឃើញជាសាធារណៈ/ យុទ្ធនាការប្រព័ន្ធឃោសនាពតិមាន
- ជួបប្រជុំជាមួយគណៈកម្មាការ
- ផ្តល់ការស្តាប់ស្ទង់ ការសិក្សាអត្ថបទពង្រាងផ្សេងៗ
នីតិវិធីបង្កើតច្បាប់
- ជំរុញក្រុមប្រឹក្សារដ្ឋធម្មនុញ្ញត្រួតពិនិត្យនូវធម្មនុញ្ញភាព
- ផ្តល់សំណើរធ្វើវិសោធនកម្ម
ច្បាប់ដែលជា ផលិតផលសំរេច

## ១) វិធីបង្កើតយុទ្ធសាស្ត្របញ្ចុះបញ្ចូលមួយៈ

### I) ការរៀបចំ

សកម្មជនដែលធ្វើការបញ្ចុះបញ្ចូល ត្រូវត្រៀមលក្ខណៈឱ្យបានល្អមុននឹងចាប់ផ្តើមធ្វើសកម្មភាពទាំងឡាយរបស់ខ្លួន ។ ពួកគេ ត្រូវ**ដឹងឱ្យបានច្បាស់លាស់នូវអ្វីដែលពួកគេចង់បាន** មុននឹងព្យាយាមជះឥទ្ធិពលទៅលើសាធារណជន និងទៅលើដំណើរការបង្កើតច្បាប់ ។ ពួកគេ **ត្រូវមានពត៌មានច្បាស់លាស់** ដើម្បីឆ្លើយសំណួរទាំងឡាយរបស់មនុស្សដែលពួកគេទាក់ទង និងសួរពួកគេដោយជៀសមិនផុត ។ ពួកគេ គួរ**ដឹងអំពីដំណោះស្រាយផ្សេងៗគ្នាដទៃទៀតដែលអាចមាន** និងដឹងផងដែរអំពីគោលជំហរ នឹងការជជែកតវ៉ារបស់មនុស្សដែលជំទាស់ និងគោលបំណងរបស់ខ្លួន ។ ជាចុងក្រោយវាមានការចាំបាច់ថា សកម្មជនដែលធ្វើការបញ្ចុះបញ្ចូល ត្រូវបង្ហាញឱ្យឃើញនូវ**គោលនយោបាយដែលបានការរៀបចំច្បាស់លាស់ (ទិសដៅនយោបាយ)** ដែលពួកគេអាចពន្យល់តាមរបៀ សាមញ្ញខ្លី ងាយយល់ ទៅកាន់មនុស្សទាំងឡាយដែលពួកគេទាក់ទង ។

ការរៀបចំដែលល្អមានបួនដំណាក់កាលៈ

- កំនត់ឱ្យឃើញបញ្ហា

  ឧទាហរណ៍ៈ

  ប្រពន្ធនិងកូនត្រូវប្តី និងឪពុករបស់ខ្លួនវាយធ្វើបាប ។ ពួកគេ ត្រូវការការការពារជាបន្ទាន់ និងដែលមានប្រសិទ្ធិភាពទល់នឹងអំពើហិង្សាក្នុងគ្រួសារនេះ ។

- ប្រមូល**ពត៌មាន**ទាំងអស់ដែលមាន

  ឧទាហរណ៍ៈ

  ធ្វើការពិនិត្យអង្កេតថា តើបញ្ហាអំពើហិង្សាក្នុងគ្រួសារមានទំហំធំជាក់ស្តែងប៉ុណ្ណោះ ២៥-៣០% ក្នុងចំណោមស្ត្រីខ្មែរទាំងអស់ទទួលរងគ្រោះអំពើហិង្សា ។ រកឱ្យឃើញថា ការការពារនោះល្អយ៉ាងដូចម្តេច ។ លទ្ធផលនៃការអង្កេត មានករណីតិចតួចប៉ុណ្ណោះ ដែលជនរងគ្រោះទទួលបានការការពារគ្រប់គ្រាន់ពីតុលាការ ប៉ូលីស និងតុលាការឧក្រិដ្ឋកម្ម ។

- ពិភាក្សា**ដំណោះស្រាយ**ផ្សេងៗគ្នា

  ឧទាហរណ៍ៈ

  អាចមានដំណោះស្រាយផ្សេងៗគ្នាចំពោះបញ្ហាៈ ក) ពង្រឹងការដាក់ទណ្ឌកម្មព្រហ្មទណ្ឌលើជនដៃដល់ ឬចារី (ប៉ុន្តែ ការផាកពិន័យ និងការដាក់គុក បណ្តាលឱ្យគ្រួសារគ្មានអ្នកទំនុកបំរុង) ខ) តាមដានឱ្យបានឆាប់រហ័សលើទំរង់ ការលែងលះគ្នា ដែលរួមមានការអនុវត្តន៏ការសងជំងឺចិត្ត និង**ការបង់ប្រាក់ឧបត្ថម្ភ** (ប៉ុន្តែ ស្ថានភាពអាក្រក់របស់ស្ត្រីដែលនៅឯកោជាមួយកូន) គ) បញ្ឈប់ជាបន្ទាន់នូវអំពើហិង្សាដោយប៉ូលីស ឬបទបញ្ជាតុលាការរដ្ឋប្បវេណី ដាក់ឱ្យបុរសនៅក្រៅផ្ទះរបស់ខ្លួនមួយរយៈ ។

- **រៀបចំគោលនយោបាយ** ( = ទិសដៅនយោបាយ)

ឧទាហរណ៏ៈ

ការពិភាក្សាដែលបានលើកឡើងពីខាងលើអំពីដំណោះស្រាយនានា អាចនាំឱ្យមានការសន្និដ្ឋានថា ដំណោះស្រាយនៅចំនុច គ) អាចជាដំណោះស្រាយដែលសមស្រប និង មានប្រសិទ្ធិភាពបំផុត ។ ហេតុដូច្នេះ ទិសដៅនយោបាយ (នយោបាយ) ត្រូវបង្កើតឡើង ដូចនេះ:

- យើងត្រូវការច្បាប់ពិសេសមួយស្ដីពីអំពើ ហិង្សាក្នុងគ្រួសារ ។
- ច្បាប់នេះ ត្រូវអនុញ្ញាតឱ្យប៉ូលីស ឬតុលាការរដ្ឋប្បវេណី ចេញដីការឱ្យបណ្ដេញប្ដីដែលប្រព្រឹត្តអំពើហិង្សាឱ្យនៅក្រៅផ្ទះមួយរយៈ ។
- កត្តានេះ នាំឱ្យមានការធូរស្បើយយ៉ាងឆាប់រហ័សសំរាប់ជនរងគ្រោះ ធ្វើឱ្យប្ដីស្ងប់ចិត្ត និងបង្រៀនពួកគេនូវមេរៀនមួយ ប៉ុន្តែក៏បានទុកឱ្យមានការសំរុះសំរួល និងជីវិតនាពេលអនាគតសំរាប់គ្រួសារផងដែរ

នៅពេលដែល សកម្មជនដែលធ្វើការបញ្ចុះបញ្ចូល បានបង្កើតគោលនយោបាយមួយដែលពួកគេចង់ផ្សព្វផ្សាយ ពួកគេត្រូវត្រួត**ពិនិត្យមើលធនធានទាំងឡាយរបស់ខ្លួន** ។ ពួកគេត្រូវធ្វើដូច្នេះ មុនពេលធ្វើពង្រាងផែនការយុទ្ធសាស្ត្រសំរាប់សកម្មភាពតស៊ូមតិឱ្យបានស៊ីជំរៅ ។ បើមិនដូច្នោះទេ ពួកគេនឹងចំណាយពេលឥតប្រយោជន៏ក្នុងការបង្កើតវិធានការនានា ដែលបង្ហាញថា គ្មានលក្ខណៈប្រាកដនិយមទាក់ទងទៅនឹងមធ្យោបាយ និងធនធានជាក់ស្ដែងដែលអ្នកធ្វើការបញ្ចុះបញ្ចូលទាំងនេះមានពិតប្រាកដ ។

គេត្រូវឆ្លើយសំណួរដូចខាងក្រោមនេះ

- **តើពេលវេលាកំណត់អ្វីដែលមាន?**
- **តើយើងមានធនធានអ្វីខ្លះ?** (បុគ្គលិក/ថវិកា/បន្ទប់)
- **តើអ្វីខ្លះជាចំណុចខ្លាំង/សមត្ថភាពរបស់យើង?**
- **តើអ្វីជាបរិបទទូទៅផ្នែកវប្បធម៌/សង្គម/នយោបាយ និងសេដ្ឋកិច្ច?**

## II) ការធ្វើផែនការលំអិតសំរាប់ការធ្វើសកម្មភាពបញ្ចុះបញ្ចូលៈ

មានសំណួរចំនួន៤ ផ្សេងគ្នាដែលត្រូវគិតពិចារណានៅពេលធ្វើផែនការយុទ្ធសាស្ត្របញ្ចុះបញ្ចូលឱ្យលំអិតៈ

- **នរណានឹង**ធ្វើការបញ្ចុះបញ្ចូល? (**តួអង្គ**)

**ពលរដ្ឋមួយរូប** អាចព្យាយាមធ្វើការបញ្ចុះបញ្ចូលបាន ។ ប៉ុន្តែ វាទំនងភាគច្រើនបំផុតថា ធ្វើដូច្នេះ វាមិនមានប្រសិទ្ធិភាពទេ ដោយសារអ្នកនយោបាយនានា និងសាធារណជនជាទូទៅ មានប្រតិកម្មឆ្លើយតបចំពោះក្រុមមនុស្សដែលមានចំនួនច្រើនជាងតែប៉ុណ្ណោះ ។ **បុគ្គលមួយក្រុម** អាចធ្វើការបញ្ចុះបញ្ចូលដោយរួមផ្សំនូវកំលាំងពតិមាន សមត្ថភាព និង ថវិការបស់ពួកគេ ។ ដើម្បីធ្វើឱ្យការងារនេះកាន់តែមានប្រសិទ្ធិភាពថែមទៀត ពួកគេត្រូវបង្កើតសម្ពន្ធ័ភាពមួយ **ឬសមាគមមួយជាមួយក្រុមដទៃទៀត** ដែលដើរទៅរកទិសដៅ ដូចគ្នា ។

ឧទាហរណ៍:

ក្រុមស្ត្រីខ្មែរទាំងអស់ ដែលមានបំណងធ្វើការបញ្ចុះបញ្ចូលឱ្យមានសិទ្ធិច្រើនជាងនេះ និងច្បាប់ល្អប្រសើរជាង ដើម្បីការពារស្ត្រីបានរួបរួមគ្នាជាសម្ព័ន្ធភាពដ៏ធំមួយដែលគេហៅថា CAMBOW (អង្គការស្ត្រីកម្ពុជា) ដើម្បីបង្កើនឥទ្ធិពលរបស់ពួកគេ ។

- **នរណាខ្លះដែលយើងត្រូវធ្វើការបញ្ចុះបញ្ចូល?** (**អ្នកទទួល**)

គេត្រូវ**កំណត់ឱ្យឃើញអ្នកសំដែងតួសំខាន់ៗ**ចំពោះដំណើរការបង្កើតច្បាប់ ។

ឧទាហរណ៍:

នរណាជាប្រធាន**គណៈកម្មការ**និមួយៗ (ដូចជា "គណៈកម្មការ កិច្ចការនារី") របស់សភាជាតិ និងព្រឹទ្ធសភា?

តើក្រុមដទៃទៀតមានឥទ្ធិពលអ្វីខ្លះទៅលើដំណើរការបង្កើតច្បាប់ (ឧទាហរណ៍: **គណបក្សនយោបាយទាំងឡាយ** ។ នរណាខ្លះនៅក្នុងគណបក្សទាំងនេះដែលទទួលបន្ទុកកិច្ចការស្ត្រី?) ។ នរណាខ្លះជាមន្ត្រីរាជការដែលជាប់ពាក់ព័ន្ធក្នុង**ក្រសួង** ដែលធ្វើពង្រាងច្បាប់? តើ**តំណាងរាស្ត្រ**ណាមួយដែលមានការចាប់អារម្មណ៍លើប្រធានបទនោះ ហើយបានផ្តល់សញ្ញាគាំទ្រ? តើអ្នកទាំងអស់នោះនៅឯណា? តើគេអាចជួប**ប្រាស្រ័យទាក់ទង**អ្នកទាំងនេះ (តាមសំបុត្រអេឡិចត្រូនិច តាមការនិយាយ ជាមួយដោយផ្ទាល់) ដោយវិធីណា? អ្វីខ្លះជា**សាវតា**គ្រួសារគោលជំហរនយោបាយរបស់ពួកគេ? តើមណ្ឌលបោះឆ្នោតរបស់ពួកគេនៅឯណា នៅខេត្តណាមួយ?

- **ពេលណាដែលយើងធ្វើការបញ្ចុះបញ្ចូល?** (**ការកំណត់ពេល**)

ឧទាហរណ៍:

ពេលវេលាដែលល្អអាចជារយៈពេលខ្លីមួយមុនការបោះឆ្នោត ដោយសារគេអាចនិយាយទៅកាន់តំណាង-រាស្ត្រភាគច្រើនដោយផ្ទាល់ នៅពេលដែលពួកគេធ្វើដំណើរទស្សនកិច្ចមណ្ឌលបោះឆ្នោតរបស់ពួកគេនៅតាមស្រុក ដើម្បីប្រមូលការគាំទ្រ ។

វាជាការល្អមួយផងដែរ ក្នុងការជ្រើសរើសថ្ងៃទិវានារីអន្តរជាតិសំរាប់សកម្មភាពប្រឆាំងនឹងអំពើហិង្សាក្នុងគ្រួសារ ដោយសារចំណាប់អារម្មណ៍របស់សាធារណជន បានផ្តោតទៅលើប្រធានបទទាក់ទងនឹងស្ត្រី រួចហើយ ។

ប៉ុន្តែវាអាចជាការកំណត់ពេលមិនល្អមួយ ដើម្បីធ្វើការបញ្ចុះបញ្ចូល នៅពេលដែលប្រធានបទដទៃទៀតដែលមានសារៈសំខាន់ជាង ត្រូវបានគេលើកយកមកពិភាក្សាក្នុងរបៀបវារៈនយោបាយ ហើយប្រធានបទដែលមានសារៈសំខាន់ជាងទាំងនេះ ទទួលបានការចាប់អារម្មណ៍ពីសាធារណជន (ឧទាហរណ៍: នៅពេលដែលមនុស្សគ្រប់គ្នានិយាយអំពីកុប្បកម្មប្រឆាំងនឹងជនជាតិថៃ នៅខែមករា ឆ្នាំ ២០០៣) ។

- តើយើងត្រូវធ្វើការបញ្ចុះបញ្ចូលដោយ**របៀបណា?** (**សកម្មភាពបញ្ចុះបញ្ចូល**)

មានសកម្មភាពបញ្ចុះបញ្ចូលជាច្រើន ដែលអាចកើតមាន:

**ជួបប្រជុំជាមួយឥស្សរជនសំខាន់ៗ:**

- ប្រជុំជាក្រុមតូច: ផ្តល់ពតិមាន និងការពិនិត្យអង្កេតទៅកាន់តំណាងរាស្ត្រ ប្រធានគណៈកម្មការ មន្ត្រីក្រសួងនានា ដោយបង្ហាញអំពីរឿងរ៉ាវរបស់ជនរងគ្រោះ (រឿងក្តី) សាកសួរ និងធ្វើបទសម្ភាសន៍ជនរងគ្រោះនោះ ។

- កិច្ចប្រជុំជាសាធារណៈ អញ្ជើញឱ្យចូលរួមក្នុងសិក្ខាសាលា សន្និសីទ ដោយផ្តល់អាស័យដ្ឋានទាក់ទងជាមួយជនរងគ្រោះ រៀបចំឱ្យមានសិក្ខាសាលា ។

**បុគ្គលដែលមានប្រជាប្រិយភាពគាំទ្រប្រធានបទបញ្ចុះបញ្ចូលៈ**

ដូចឧទាហរណ៍នៃសេចក្តីថ្លែងការណ៍ជាសាធារណៈ លិខិតគាំទ្រ ឬយ៉ាងហោចណាស់មានហត្ថលេខាមួយរបស់សិល្បៈករ សិល្បៈការិនី ឬព្រះហស្ថលេខារបស់សម្តេច ឬរបស់កីឡាករ អ្នកចំរៀង អ្នកនិពន្ធ/អ្នកផលិតខ្សែភាពយន្ត ។

ឧទាហរណ៍ៈ

យុទ្ធនាការរបស់ក្រសួងកិច្ចការនារី បានបង្កើតនូវខ្សែភាពយន្តខ្លីមួយដែលមានអត្ថន័យប្រឆាំងនឹងអំពើហិង្សាក្នុងគ្រួសារ ដែលសំដែងដោយសិល្បៈការិនីខ្មែរដ៏ល្បីល្បាញម្នាក់ ។

**បង្កើតព្រឹត្តិការណ៍ ដើម្បីទាក់ទាញការចាប់អារម្មណ៍របស់សាធារណជនៈ**

ធ្វើដំណើរទស្សនកិច្ចទៅតាមខេត្ត ដោយមានពតិមានផ្សព្វផ្សាយបិទជាប់នឹងរថយន្តធ្វើដំណើរ ការសំដែងល្ខោន ការប្រារព្ធពិធីបុណ្យ ការប្រគុំតន្ត្រី ការរៀបចំល្បែងប្រណាំងគ្នា (គូររូបប្រណាំងគ្នា ការប្រណាំងស៊ីក្លូ ការប្រឡងសរសេរលើប្រធានបទ ដែលនៃការបញ្ចុះបញ្ចូល) បង្កើតទិវាពិសេសមួយ ផ្តល់រង្វាន់ដល់តំណាងរាស្ត្រ ឬបុគ្គលដទៃទៀត ដែលបានបង្ហាញការប្តេជ្ញាចិត្តយ៉ាងសកម្ម ជាពិសេសចំពោះប្រធានបទដែលគេធ្វើការបញ្ចុះ-បញ្ចូល ការដាក់ជូនជាសាធារណៈនូវសំណើរច្បាប់របស់ខ្លួនដែលធ្វើឡើងដោយអង្គការ ក្រៅរដ្ឋាភិបាលជូនប្រធានរដ្ឋសភា ។

ឧទាហរណ៍ៈ

យុទ្ធនាការប្រឆាំងជំងឺគ្រុនចាញ់ បានរៀបចំឱ្យមានការប្រណាំងស៊ីក្លូមួយនៅទីក្រុងភ្នំពេញ និងបានបោះពុម្ពសៀវភៅរឿងកំប្លែង ។ ក្មេងតាមចិញ្ចើមថ្នល់ បានរៀបចំឱ្យមានសភាក្មេង ដើម្បីឱ្យសាធារណជនស្តាប់ឮសំលេងរបស់ពួកគេ និងដើម្បីបោះពុម្ពជាឯកសារអំពីតំរូវការរបស់ពួកគេ ។ យុទ្ធនាការប្រឆាំងនឹងជំងឺអេដស៍ បានធ្វើដំណើរពាសពេញប្រទេសដោយមានសំដែងអាយ៉ង ដើម្បីបង្រៀនប្រជាជនឱ្យយល់ដឹងអំពីបញ្ហាអេដស៍ ។ មជ្ឈមណ្ឌលកម្ពុជាសំរាប់សិទ្ធិមនុស្ស បានរៀបចំការសំដែងល្ខោននៅតាមខេត្តអំពីប្រធានបទសិទ្ធិមនុស្ស ។

**សកម្មភាពរបស់មហាជនៈ**

ចែកចាយនូវកូនលិខិតជាសាធារណៈ ដែលមានហត្ថលេខា/ស្នាមផ្តិតមេដៃរាប់ពាន់ ការធ្វើបាតុកម្មនៅមុខសភា ការស្ងៀមស្ងាត់មួយនាទីធ្វើឡើងទូទាំងប្រទេសសំរាប់បុព្វហេតុពិសេសណាមួយ ការដុតបំភ្លឺទៀនគឺជាមធ្យោបាយមួយដែលមានសន្តិភាពបំផុត ដើម្បីបង្ហាញការគាំទ្ររបស់មហាជន ។

ឧទាហរណ៍ៈ

អង្គការស្ត្រីកម្ពុជា (CABMOW) បានរៀបចំក្បួនដើរដង្ហែដែលមានស្ត្រីចំនួន ៦០០នាក់ ពាសពេញតាមដងផ្លូវទីក្រុងភ្នំពេញដើម្បីលើកកំពស់ការយល់ដឹងអំពី សិទ្ធិរបស់ស្ត្រី ។

**ប្រពន្ធ័ផ្សព្វផ្សាយពតិមានៈ**

កម្មវិធីទូរទស្សន៍/វិទ្យុ ការជជែកពិភាក្សាលើវេទិកា លិខិតផ្ញើរជូនអ្នកនិពន្ធអត្ថបទនៅក្នុងសារពតិមានទស្សនាវដ្តីអំពីប្រធានបទធ្វើការបញ្ចុះបញ្ចូល ។

**ករណីសាកល្បងនៅតុលាការៈ**

ប្តឹងទៅតុលាការ ចំពោះករណីមួយដែលមានការចុះផ្សព្វផ្សាយច្រើន ។ ប្រើប្រាស់នីតិវិធីតុលាការ ធ្វើជាឆាកផ្សព្វផ្សាយ និងសំរាប់បង្ហាញបញ្ហាទៅសាធារណជនតាមរយៈរឿងក្តីជាឧទាហរណ៍ណាមួយ ។

## ឧទាហរណ៍ល្អៗមួយចំនួនចំពោះសកម្មភាពបញ្ចុះបញ្ចូលនៅព្រះរាជាណាចក្រកម្ពុជា៖

យុទ្ធនាការប្រឆាំងនឹងជំងឺអេដស៍ ធ្វើដំណើរនៅជុំវិញ
ខេត្តនានា ជាមួយការសំដែងអាយ៉ងមួយ (ភ្នំពេញប៉ុស្តិ៍
ចេញផ្សាយថ្ងៃទី ២១ ខែកក្កដា ឆ្នាំ ២០០២)




PSI's traveling puppet show. The performers illustrate to crowds of up to 20,000 around the country the importance of safe sex.

children want:

Recommendations by 45 children from across Cambodia to the nation's lawmakers May 30 were:

- Increase the national budget for education, health, social affairs and protection.
- Create a children's ombudsman so children and victims can receive protection.
- Set up a juvenile justice system for children.
- Ratify ILO Convention 182 concerning the prohibition of the worst forms of child labor.
- Implement adoption laws.
- Increase the age of criminality.
- Push for law enforcement in order to eliminate violence to children and domestic violence.
- Enforcement of law for child abusers and child traffickers.
- Elimination of judicial and police corruption.
- Separate incarcerated children from the adults and put them in rehabilitation centers.
- Enforce birth registration for all children.
- Encourage education on rights of the child for judges, law enforcers, government officials, teachers, prison officials and health and social staff.

ក្មេងៗ បានអំពាវនាវទៅកាន់អ្នកធ្វើច្បាប់ និង
ផ្សព្វផ្សាយបំណងប្រាថ្នាជាក់លាក់មួយចំនួន (ភ្នំពេញប៉ុស្តិ៍
ចេញផ្សាយថ្ងៃទី ៧ ខែកក្កដា ឆ្នាំ ២០០២)

អ្នកបញ្ចុះបញ្ចូលឱ្យមានយុទ្ធនាការប្រឆាំងនឹងថ្នាំជក់បានរៀបចំ
ការប្រណាំងស៊ីក្លូមួយដែលនាំឱ្យមានការចាប់អារម្មណ៍យ៉ាងខ្លាំងអំពីគោលបំណងរបស់ពួកគេ
(ខេមបូឌាដេលី ចេញផ្សាយថ្ងៃទី ៧ ខែមិថុនា ឆ្នាំ ២០០២)

The CAMBODIA DAILY — FRIDAY, JUNE 7, 20

NATIONAL



Heng Chivoan

LUNG POWER - A cyclo driver powers by Wat Phnom Thursday during an anti-tobacco rally in Phnom Penh. Dozens of cyclo drivers in the capital participated in the race, which was designed to help draw attention to anti-tobacco campaigns. World Health Organization country representative Jim Tulloch said the event was timed to coincide with the World Cup, during which lobbyists have successfully pushed for a ban on tobacco sales.

## III) វិធានមាសសំរាប់ធ្វើការបញ្ចុះបញ្ចូលៈ

មានវិធានមួយចំនួនដែលគេត្រូវគោរពទៅតាមនៅរាល់ដំណាក់កាលនៃសកម្មភាពបញ្ចុះបញ្ចូល ដើម្បីធ្វើឱ្យប្រាកដថា រាល់សកម្មភាពទាំងនេះនឹងទទួលបានជោគជ័យ (អ្នកអាចរកបានវិធានបែបនេះបានច្រើនជាងនេះតាមរយៈគេហទំព័រផ្សេងៗស្តីអំពីការរៀបចំការបញ្ចុះបញ្ចូល និងការតស៊ូមតិ សូមអានខាងក្រោម) ប៉ុន្តែវិធាន បីខាងក្រោមទំនងជាវិធានជាមូលដ្ឋានបំផុតៈ

- ធ្វើឱ្យខ្លី
- ប្រកាន់ខ្ជាប់សច្ចៈធម៌ និងហេតុការណ៍ពិត
- ជៀសវាងការគំរាមកំហែង/ត្រូវមានលក្ខណៈប្រកបដោយការស្ថាបនា និងគួរសម

ហេតុផលសំរាប់វិធានទាំងនេះគឺថាៈ

ប្រសិនបើ អ្នកមិនអាចបង្ហាញពីបុព្វហេតុរបស់អ្នកឱ្យបានច្បាស់លាស់ **ខ្លី ងាយយល់ និងតាមរចនាសម្ព័ន្ធ**ទេ គ្មាននរណាម្នាក់នឹងស្តាប់អ្នកទេ ។ គេត្រូវរៀបចំទិសដៅនយោបាយតាមវិធីសាមញ្ញដើម្បីឱ្យមនុស្សគ្រប់គ្នាអាចយល់ដឹងពីទិសដៅទាំងនេះ ។ តំណាងរាស្ត្រ អ្នកការិយាល័យធិបតេយ្យនិយម មន្ត្រីសំខាន់ៗ ជាទូទៅមិនមានពេលវេលាច្រើន ដើម្បីស្តាប់នោះទេ ។ ប្រជាជនទូទៅ ជាធម្មតាក៏មិនមានពេលវេលាច្រើនសំរាប់ការពិភាក្សាផ្នែកនយោបាយដែរ ។ លើសពីនេះទៅទៀត ភាគច្រើននៃមនុស្សជាទិសដៅទាំងនេះ ក្នុងការបញ្ចុះ-បញ្ចូល អាចមិនមែនជាអ្នកជំនាញលើប្រធានបទដែលអ្នកបានធ្វើការបញ្ចុះបញ្ចូល ។ ហេតុដូច្នេះ អ្នកត្រូវប្រាប់ពួកគេឱ្យបានច្បាស់លាស់នូវបញ្ហាអ្វីពិតប្រាកដ អ្វីជាដំណោះស្រាយរបស់អ្នក អ្វីដែលអ្នកចង់សំរេចឱ្យបានពិតប្រាកដ និងអ្វីដែលមនុស្សជាទិសដៅអាចធ្វើបានក្នុងការគាំទ្រដល់អ្នក ។

ឧទាហរណ៍ៈ

ប្រសិនបើ អ្នកធ្វើការបញ្ចុះបញ្ចូលឱ្យមានការធ្វើវិសោធនកម្មលើមាត្រាមួយរបស់រដ្ឋធម្មនុញ្ញ អ្នកគួរតែបង្ហាញអត្ថបទនៃមាត្រានេះ បង្ហាញអត្ថបទដែលបានធ្វើវិសោធនកម្មដែលអ្នកបានស្នើឡើង និងលើកឡើងនូវហេតុផលមួយ ឬពីរចំពោះសំណើររបស់អ្នក ។

អ្នកអាចទទួលជោគជ័យបាន លុះត្រាតែអ្នកប្រកាន់ខ្ជាប់នូវសច្ចៈធម៌ ។ **ការបញ្ចុះបញ្ចូលមានន័យថាជាការអូសទាញ** និងធ្វើឱ្យអ្នកដទៃទៀតជឿតាមខ្លួន ។ ប៉ុន្តែ ការបញ្ចុះបញ្ចូល **មិនមែនមានន័យថាជាការអូសទាញ**មនុស្សអូសជឿតាមខ្លួន ដោយសារប្រើប្រាស់កលល្បិច ការចោទប្រកាន់មិនពិតប្រាកដ និងមធ្យោបាយដទៃទៀតបែបនេះនោះទេ ។ ត្រូវផ្តល់ហេតុការណ៍ពិត និងពត៌មានឱ្យបានច្បាស់លាស់ ដកស្រង់ការពិនិត្យអង្កេត បោះពុម្ពបទសម្ភាសន៍ជាមួយជនរងគ្រោះ ធ្វើឧទ្ទេសនាមអំពីករណីសិក្សានានា ។ ទាំងនេះគឺជាឧបករណ៍របស់អ្នក ដើម្បីធ្វើឱ្យអ្នកដទៃទៀតជឿតាម ។

ការវិនិច្ឆ័យ ការចោទប្រកាន់ ឬការរិះគន់តាមពាក្យសំដីធ្ងន់ធ្ងរ នឹងមិនជួយបង្កើតឱ្យមានបរិយាកាសគាំទ្រចំពោះបុព្វហេតុរបស់អ្នកទេ ។ ហេតុដូច្នេះ **លក្ខណៈគួរសម និងប្រកបដោយការស្តាបនា** គឺជាមធ្យោបាយដែលអំណោយផលតែមួយគត់ក្នុងការសំរេចបានជោគជ័យ ។ ជាការពិតណាស់ ហេតុការណ៍ពិត និងពតិមានដែលមិនគួរជាទីពេញចិត្តត្រូវលើកយកមកបង្ហាញឱ្យដឹង ហើយមិនត្រូវប្រឌិតទេ ប៉ុន្តែមនុស្សជាទិសដៅរបស់អ្នកប្រហែលជាគិតថា អ្នកមានការចាប់អារម្មណ៍ ក្នុងការស្វែងរកដំណោះស្រាយជាវិជ្ជមានដែលជាបញ្ហាដែលទាក់ទងទៅនឹងបុគ្គលដែលពាក់ព័ន្ធទាំងអស់ ។ ហេតុដូច្នេះ អ្នកក៏ត្រូវដឹងផងដែរ អំពីទស្សនៈយល់ឃើញផ្ទុយពីអ្នក និងក្រុមដែលមិនចូលចិត្តគំនិតរបស់អ្នក ។ អ្នកក៏ត្រូវគិតពិចារណាអំពីគោលជំហររបស់ពួកគេផងដែរ ។

## IV) គេហទំព័រអ៊ិនធឺណែតសំខាន់ៗសំរាប់ការបញ្ចុះបញ្ចូល

អង្គការអន្តរជាតិជាច្រើនបានផ្តល់នូវគំនិត ឧបករណ៍ និងយុទ្ធសាស្ត្រសំរាប់សកម្មភាពតស៊ូមតិ[៣៤] ។ ការបើកមើលគេហទំព័រអ៊ិនធើណិត[៣៥] របស់អង្គការទាំងនេះ អាចជួយផ្តល់ឱ្យមានគំនិតច្រើនថែមទៀតអំពីវិធីធ្វើការបញ្ចុះបញ្ចូល យុទ្ធសាស្ត្រអ្វីដែលត្រូវជ្រើសរើស និងបញ្ហាផ្សេងៗទៀត ។

១) នៅលើគេហទំព័ររបស់ឧត្តមស្នងការជាន់ខ្ពស់នៃអង្គការសហប្រជាជាតិសំរាប់សិទ្ធិមនុស្ស អ្នកអាចរកឃើញ "**គំនិតច្រើនជាង ៥០** សំរាប់ធ្វើការប្រារព្ធសេចក្តីប្រកាសសិទ្ធិមនុស្សជាសកល" (www.unhchr.ch/html/50th/ideas.htm) ។ **បញ្ជីរៀបរាប់សកម្មភាពនានាដែលបានស្នើឡើង** ផ្តល់នូវការត្រួតពិនិត្យដ៏ល្អមួយចំពោះសភាពពិតប្រាកដនៃបច្ចេកទេសតស៊ូមតិនានា ។

២) ពតិមានជាក់ស្តែងសំខាន់ៗយ៉ាងច្រើនអំពីការបញ្ចុះបញ្ចូល និង ការតស៊ូមតិមាននៅលើគេហទំព័រឈ្មោះ **Human Rights Connection** (**www.hrconnection.org**):

[៣៤] អង្គការ "PACT" ដែលធ្វើសកម្មភាពផងដែរនៅកម្ពុជា ផ្តល់ការបណ្តុះបណ្តាលលើការតស៊ូមតិសំរាប់អង្គការក្រៅរដ្ឋាភិបាល ។ សូមមើល www.pactworld.org ។
ការបណ្តុះបណ្តាលថែមទៀតរបស់អង្គការ PACTS មាននៅលើ: www.pactworld.org/programs/sectoral/advocacy/index-advocacy.htm

[៣៥] អង្គការ "developmentgateway" ផ្តល់នូវបញ្ជីទំនាក់ទំនងចំពោះប្រភេទផ្សេងៗគ្នានៃអង្គការក្រៅរដ្ឋាភិបាលដែលធ្វើការតស៊ូមតិ និងអត្ថបទសំខាន់ៗ ដែលពាក់ព័ន្ធ: សូមមើល www.developmentgateway.org/node/130664




ជាឧទាហរណ៍ចុចលើ "Media" ដើម្បីស្វែងរកពត៌មានសំខាន់ៗអំពីវិធីប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយពត៌មានៈ នៅទីនេះ អ្នកអាចរកឃើញគោលការណ៍ណែនាំមួយស្ដីពីវិធីសរសេរ**សេចក្ដីប្រកាសពត៌មាន** ដែលរួមមានអត្ថបទនៃសេចក្ដីប្រកាសពត៌មានជាឧទាហរណ៍ ។ ឬក៏អ្នកនឹងអាចរកឃើញនូវពត៌មានអំពីវិធីធ្វើ**បទសម្ភាសន៏** ឬវិធីផ្ដល់បទសម្ភាសន៏។ លើសពីនេះទៅទៀត អ្នកនឹងរកឃើញការណែនាំអំពីការសរសេរ**លិខិតទៅកាន់អ្នកនិពន្ធ** ។ អត្ថបទពត៌មានទាំងអស់ មានឧទាហរណ៍ជាក់ស្ដែងជាច្រើន។

ឬក៏ចុចទៅលើ "Advocacy" រួចហើយ អ្នកនឹងឃើញមានគោលការណ៍ណែនាំជាច្រើនសំរាប់ប្រធានបទផ្សេងៗគ្នា ដូចជា "**ការកំណត់ពេលវេលាៈ** ធ្វើឱ្យ យុទ្ធសាស្ដ្រសមស្របទៅតាមរយៈពេល" ។ នៅពេលដែលអ្នកចុចលើ "Advocacy" អ្នកក៏ឃើញផងដែរនូវ**ការសិក្សារឿងក្ដី**ចំនួនបី ដែលសរសេរដោយអ្នកដែលមានវិជ្ជាជីវៈរបស់អង្គការក្រៅរដ្ឋាភិបាល ដែលបង្ហាញអំពីបែបផែន ដែលយុទ្ធសាស្ដ្រដំណើរការតស៊ូមតិពិតប្រាកដក្នុងស្ថានភាពជាក់ស្ដែង (ឧទាហរណ៍ អំពីយុទ្ធនាការប្រឆាំងនឹងការរំលោភបំពានលើកុមារនៅតណ្ឌា) ។

៣) ប្រសិនបើអ្នកចង់រកអត្ថបទជាទូទៅអំពីពត៌មានលំអិត និងយុទ្ធសាស្ដ្រតស៊ូមតិទាំងអស់ និងជាពិសេស អំពីការបញ្ចុះបញ្ចូល អ្នកអាចរកឃើញគ្រាន់តែបើកមើលគេហទំព័រដែលមានអាស័យដ្ឋានដូចខាងក្រោមៈ **(www.advocacy.org.za/sector.php?sector_type=DB)** ។ នៅពេលដែលអ្នកចុចទៅលើអាស័យដ្ឋាននេះ អ្នកនឹងឃើញបញ្ជីអត្ថបទដ៏វែងមួយអំពីប្រធានបទផ្សេងៗគ្នា ដែលរៀបរៀងតាមកាលប្បវត្តិ ។

ប្រសិនបើ អ្នកសំឡឹងមើលកាលបរិច្ឆេទ ថ្ងៃព្រហស្បតិ៍ ទី ១២ ខែធ្នូ ឆ្នាំ ២០០២ អ្នកនឹងឃើញអត្ថបទមួយមានឈ្មោះថា "**មគ្គុទេសក៏ណែនាំ ជាមូលដ្ឋានសំរាប់ការតស៊ូមតិ និងការបញ្ចុះបញ្ចូល (A basic guide to advocacy and lobbying)** " និង "**វិធានមាសសំរាប់ការតស៊ូមតិ និងការបញ្ចុះបញ្ចូល (Golden rules of advocacy and lobbying)**" ។ អ្នកអាចថតចំលងអត្ថបទនេះ ហើយអ្នកនឹងឃើញនូវអនុសាសន៍ជាច្រើនលើវាល់ទិដ្ឋភាពនៃការបញ្ចុះបញ្ចូលដែលជាទូទៅមានសារៈសំខាន់ ទោះបីជា ពតិមានមួយចំនួនសំដៅជាពិសេសចំពោះរដ្ឋទ្វីបអាហ្វ្រិក នៅក្នុងប្រទេស Zimbabwe ជាទីកន្លែងដែលគេបង្កើតគេហទំព័រនេះក៏ដោយ ។

# ការបញ្ចុះបញ្ចូល

| ការរៀបចំ | យុត្តិសាស្ត្រ | វិធានមាសសំរាប់ការបញ្ចុះបញ្ចូល |
|---|---|---|
| កំណត់បញ្ហា | អ្នកណាត្រូវទៅបញ្ចុះបញ្ចូល ? | ធ្វើយ៉ាងម៉េចឱ្យខ្លី |
| ប្រមែប្រមូលពិតមានដែលចាំបាច់ទាំងអស់ | ត្រូវទៅបញ្ចុះបញ្ចូលអ្នកណា ? | សង្កត់ទៅលើការពិត និងអង្គហេតុ |
| ពិភាក្សារកដំណោះស្រាយបញ្ហាផ្សេងៗ | ពេលណាទៅបញ្ចុះបញ្ចូល ? | សុភាពរាបសារ និងមានការកែលំអ |
| បង្កើតគោលនយោបាយ (គោលបំណងនយោបាយ) | តើបញ្ចុះបញ្ចូលដោយរបៀបណា ? | |
| ត្រួតពិនិត្យនូវធនធានរបស់អ្នក | | |